**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៧-១១០៨ ស.ជ.ណ

ថ្ងៃអង្គារ ០២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ គ.ស. ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)
## លើកទី ១៥

យោងតាមសេចក្តីជូនដំណឹងលេខ ធ៥.០១៧.៤១៥ ស-ជ-ណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការបង្កើនឥណប្រតិទានប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា នព្វស័កព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ គ.ស.២០១៧
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ គ.ស.២០១៧
- ឥណប្រតិទាន : ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ គ.ស.២០១៨
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ២០.០០០.០០០.០០០ (ម្ភៃប៊ីលាន) រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន) រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន) រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD (ជារៀលឬដុល្លារ) ត្រូវមានឥណប្រតិទានយ៉ាងតិច ៣៦៤ថ្ងៃ។ NCD ជាដុល្លារអាមេរិកត្រូវកំណត់ Haircut ៥% នៃទឹកប្រាក់ ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬតាមផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP) ក្នុងករណីមធ្យោបាយទាំងពីរនេះមិនដំណើរការ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការឲ្យបានមុនម៉ោង១២:០០ ថ្ងៃត្រង់ នាថ្ងៃដដែល។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្ដីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។


សូមទំនាក់ទំនង ៖

លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣

(៨៥៥-២៣) ៧២២ ២២១ EX ១០៤៨

សារអេឡិចត្រូនិក : lpco_info@nbc.org.kh